**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៤ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១០២ អនក្រ.បក**
**ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពី**
**ការទទួលស្គាល់សមាជិកជ្រើសតាំងមណ្ឌលសភាពាណិជ្ជកម្ម រាជធានីភ្នំពេញ**
**អាណត្តិទី៣ លើកទី២**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល សមាសភាពសមាជិករាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា២ និងមាត្រា១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា១០ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៦១ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីកែប្រែមាត្រា២ នៃអនុក្រឹត្យ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការទទួលស្គាល់ សមាជិកជ្រើសតាំងមណ្ឌលសភាពាណិជ្ជកម្មរាជធានីភ្នំពេញ អាណត្តិទី៣ លើកទី២
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រាមួយ.-**

មាត្រា ១ នៃអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពីការទទួលស្គាល់ សមាជិកជ្រើសតាំងមណ្ឌលសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា ១.-ថ្មី**

ត្រូវបានទទួលស្គាល់សមាជិកជ្រើសតាំងមណ្ឌលសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ចំនួន៤០រូប សម្រាប់អាណត្តិ ទី៣ លើកទី២ ដែលបែងចែកតាមប្រភេទអាជីវកម្មដូចខាងក្រោម៖

**ប្រភេទពាណិជ្ជកម្ម**

១-អ្នកឧកញ៉ា **គិត ម៉េង**
២-ជំទាវឧកញ៉ា **លឹម ឈីវហូ**
៣-ឯកឧត្តមឧកញ៉ា **ស៊ីវ ថៃ**
៤-ឧកញ៉ា **លី ហួរ**
៥-ឯកឧត្តមឧកញ៉ា **គិត មៀង**
៦-ឧកញ៉ា **គីម សាវុធ**
៧-ឧកញ៉ា **លី យុនថៃ**
៨-ឧកញ៉ា **ហ៊ីន ឡាក់**
៩-ឧកញ៉ា **អ៊ុន យុទ្ធី**
១០-ឧកញ៉ា **ខៀវ ចេងហេង**
១១-លោកស្រី **ឈឹម វត្តី**
១២-លោកស្រីឧកញ៉ា **កែវ មុំ**

**ប្រភេទឧស្សាហកម្ម**

១-ឯកឧត្តមឧកញ៉ា **ស៊ិន សុខណា**
២-ឧកញ៉ា **ហាន់ មៀង**
៣-ជំទាវឧកញ៉ា **កែវ ម៉ាលី**
៤-លោកស្រីឧកញ៉ា **ចាន់ សុផ្លា**
៥-ឧកញ៉ា **ថៃ ជាហួត**
៦-ឧកញ៉ា **លាង ម៉េង**
៧-ឧកញ៉ា **តែ តាំងប៉ះ**
៨-ឧកញ៉ា **ថៃ ហុកឈួន**
៩-ឧកញ៉ា **តែ អ៊ីនៃ**
១០-ឧកញ៉ា **លី គួយ**
១១-បណ្ឌិត **តាន់ មុនីវណ្ណ**
១២-លោក **គីម ម៉េងហ៊ួត**

**ប្រភេទសេវាកម្ម និង វិជ្ជាជីវៈសេរី**

១-ឯកឧត្តមឧកញ៉ា **ហ៊ី បាវី**
២-ឧកញ៉ា **ឌី ពិសិដ្ឋ**
៣-ឧកញ៉ា **វិញ ហ៊ួរ**
៤-ឯកឧត្តមឧកញ៉ា **គុជ ស៊ីនិត**
៥-ឧកញ៉ា **សុខ ពិសិដ្ឋ**
៦-លោក **គុយ វ៉ាត**
៧-ឧកញ៉ា **ឈឹម សុភន**
៨-លោក **គួច ផេង**
៩-លោក **លឹម សុជាតិ**
១០-ឧកញ៉ា **សុខ នេង**



www.pheakdeylaw.com

**ប្រភេទកសិកម្ម**

១-ឧកញ៉ា **ហុង ពីង**
២-ឧកញ៉ា **កែម ឡា**
៣-ឧកញ៉ា **តាំង គួង**
៤-ឧកញ៉ា **លឹម ហេង**
៥-លោកឧកញ៉ា **ឈាង សុធី**
៦-លោកឧកញ៉ា **អាន ម៉ាឌី**

**មាត្រាពីរ**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រាបី**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៧

**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ដើម្បីចុះហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com